# មេរៀនទី ៥៦៖ ស៊ីម្មាន និងអាណាអរសប្បាយ

## លូកា ២៖២២-៤០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/9xfOlzIdlbU

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/ERF91OQ-p_E

**គោលបំណង៖** យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់ព្រះយេស៊ូវ

**ខគម្ពីរចងចាំ៖ ទំនុកតម្កើង ៩៖១** *“ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្តទូលបង្គំនឹងនិទានពីអស់ទាំងការអស្ចារ្យរបស់ទ្រង់”។*

**ចំរៀង** ( *យូធូបលីង* )៖
1. ខ្ញុំសប្បាយរីករាយ https://youtu.be/2LWPsq-KZvo
2. ខ្ញុំចូលតាមទ្វារព្រះអង្គ https://youtu.be/WvXL4DtBMdc
3. អរគុណ អរគុណព្រះអង្គ https://youtu.be/MdYoscjxNeo

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត **« សប្បាយ ឬក៏ កើតទុក្ខ ?»**

សម្ភារៈដែលត្រូវការ៖ គូររូបទឹកមុខញញឹមនិងទឹកមុខក្រៀមក្រំនៅលើក្រដាស

១. ឲ្យកុមារអង្គុយជារង្វង់

២. នៅពេលដែលគ្រូបង្ហាញក្រដាស “ទឹកមុខញញឹម” កុមារទាំងអស់ត្រូវតែលោតដោយសេចក្តីអំណរនិងទឹកមុខសប្បាយរីករាយ

៣. នៅពេលដែលគ្រូបង្ហាញក្រដាស “ទឹកមុខក្រៀមក្រំ” កុមារទាំងអស់ត្រូវអង្គុយចុះជាមួយនិងទឹកមុខក្រៀមក្រំ

៤. បន្ទាប់ពីលេងល្បែងចប់សូមពន្យល់កុមារថា យើងត្រូវតែលោតរាំជាមួយទឹកមុខអំណរអរសប្បាយនៅពេលដែលយើងដឹងថា ព្រះយេស៊ូវយាងមកដើម្បីសង្គ្រោះយើង!

### ៤. ការណែនាំមេរៀន

តើអ្នកធ្វើដូចម្តេច ដើម្បីអបអរពេលដែលមានទារកទើបនឹងកើតនៅក្នុងគ្រួសារ? នៅពេលមានទារកណាកើតមកមានបងប្អូន តាយាយ អ៊ំពូមីង ដែលគាត់តែងតែនាំយក អំណោយទៅសួរសុខទុក្ខទារកមានដូចជា លុយ ខោអាវ ម្សៅ ទឹកដោះគោ ទឹកផ្លែឈើ នៅពេលកូនកើតបាន១ខែគេតែងតែធ្វើកម្មវិធីបង្កក់កូន។ នៅក្នុងព្រះគម្ពីរ នៅពេលដែលមានទារកកើតឪពុកម្តាយត្រូវយកទារកនោះ ទៅថ្វាយជាយញ្ញបូជា ដល់ព្រះជាម្ចាស់នៅឯព្រះវិហារ។ ដូច្នេះម៉ារ៉ានិងយ៉ូសែបបានយកព្រះយេស៊ូវទៅកាន់ព្រះវិហារ ដើម្បីធ្វើ យញ្ញបូជាថ្វាយព្រះជាម្ចាស់។ នៅពេលដែលព្រះយេស៊ូវប្រសូត្រមនុស្សគ្រប់គ្នាមិនបានដឹងថា ព្រះយេស៊ូវ គឺជាទារកដ៏អស្ចារ្យនោះទេ-គឺជាព្រះមេស្ស៊ីដែលសង្គ្រោះពិភពលោក។ ប៉ុន្តែនៅឯព្រះវិហារ ម៉ារ៉ា និងយ៉ូសែបបានជួបជាមួយមនុស្សពីរនាក់ដែលដឹងការពិត! តោះសូមឲ្យយើងបានរៀនពីពួកគាត់នៅថ្ងៃនេះ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅដែលពេលព្រះយេស៊ូវប្រសូតនៅភូមិបេថ្លេហិម ប្រហែលជានៅពេលនោះមានមនុស្សជាច្រើននៅក្នុងក្រុង និងក្នុងព្រះវិហារបរិសុទ្ធ។ ព្រះគម្ពីរ **លូកា ២៖២៥-២៦** បាននិយាយថា "នោះមើលនៅក្រុងយេរូសាឡិម មានមនុស្សម្នាក់ឈ្មោះស៊ីម្មាន ជាអ្នកសុចរិត ដែលកោតខ្លាចដល់ព្រះ គាត់រង់ចាំសេចក្តីដោះទុក្ខ របស់សាសន៍អ៊ីស្រាអែល ហើយព្រះវិញ្ញាណបរិសុទ្ធក៏សណ្ឋិតលើគាត់ ព្រះវិញ្ញាណបរិសុទ្ធបានសំដែងឲ្យគាត់ដឹងថា គាត់មិនស្លាប់ឡើយទាល់តែបានឃើញព្រះគ្រីស្ទនៃព្រះអម្ចាស់" ។ សាកស្រមៃមើលថា អ្នកនឹងមិនស្លាប់រហូតដល់ពេលដែលអ្នកបានជួបព្រះយេស៊ូវ។ នោះគឺជាការសន្យាពិសេសមួយដែលព្រះបានផ្តល់ឲ្យស៊ីម្មាន។

ពេលស៊ីម្មានឃើញម៉ារ៉ា និងយ៉ូសែបមានទារកក្នុងដៃគាត់ដឹងថា នេះគឺជាទារកពិសេសណាស់។ គាត់ត្រេកអរនិងដឹងគុណជាទីបំផុតដែលគាត់បានឃើញព្រះមេស្ស៊ី ទោះបីជាទ្រង់នៅក្មេងក៏ដោយ។ ស៊ីម្មានបានដឹងថា ព្រះបានរក្សាការសន្យារបស់ទ្រង់ ហើយព្រះអង្គនឹងបន្តថែរក្សារាស្ត្ររបស់ទ្រង់។

នៅថ្ងៃនេះ មិនមែនមានតែស៊ីម្មានម្នាក់ទេដែលបានជួបទារក ជាព្រះមេស្ស៊ីនោះ។ ស្ត្រីម្នាក់ឈ្មោះ អាណក៏នៅទីនោះដែរ។ នាងជាស្ត្រីមេម៉ាយមានអាយុ ៨៤ឆ្នាំ។ ព្រះគម្ពីរ **លូកា ២៖៣៧** "នៅជាមេម៉ាយប្រហែលជា៨៤ឆ្នាំ ក៏នៅតែក្នុងព្រះវិហារមិនដែលចេញឡើយ គាត់គោរពទាំងយប់ទាំងថ្ងៃ ដោយការតមហើយអធិស្ឋាន" ។ នេះមានន័យថា គាត់រស់នៅក្នុងព្រះវិហារបរិសុទ្ធ (ព្រះវិហារ) ជារៀងរាល់ថ្ងៃ។ គាត់បានអរព្រះគុណដល់ព្រះ ដែលបានអនុញ្ញាតឲ្យគាត់បានជួបនឹងព្រះយេស៊ូវជាព្រះអង្គសង្គ្រោះនៃពិភពលោក!

តើប្អូនបានអរព្រះគុណដល់ព្រះដែលបានបញ្ជូនព្រះយេស៊ូវជាព្រះអង្គសង្គ្រោះមកឯយើងដែរឬទេ? ចូរអរព្រះគុណដល់ព្រះជាម្ចាស់សម្រាប់ព្រះយេស៊ូវ ហើយសូមអរព្រះគុណព្រះយេស៊ូដែលយាងមក ដើម្បីសង្គ្រោះយើង។

## ៦. សំនួរពិភាក្សា

១. តើនរណាជាមនុស្សសុចរិត និងមានចិត្តស្មោះត្រង់ដែលបានជួបព្រះយេស៊ូវ? *(ស៊ីម្មាន)*
២. តើនរណាជាស្ត្រីមេម៉ាយដែលមានអាយុ ៨៤ឆ្នាំ ហើយបានជួបព្រះយេស៊ូវ? *(អាណា)*
៣. តើពួកគាត់បានធ្វើអ្វីនៅពេលដែលគាត់បានជួបព្រះយេស៊ូវ? *( ពួកគាត់បានធ្វើការអរព្រះគុណដល់ព្រះជាម្ចាស់)*
៤.តើកូនអាចបង្ហាញការដឹងគុណចំពោះព្រះបានយ៉ាងដូចម្តេច ដែលទ្រង់បានបញ្ជូនព្រះយេស៊ូវមកជួយសង្គ្រោះដល់យើង?*(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ស្វែងរកកំណប់»

សម្ភារៈដែលត្រូវការ៖ ស្ករគ្រាប់



១. គ្រូត្រូវយកស្ករគ្រាប់ទៅលាក់គ្រប់ទីកន្លែង នៅ ក្នុងថ្នាក់រៀនកុំឲ្យកុមារដឹង
២. យើងឲ្យកុមារដើររកស្ករគ្រាប់ ក្នុងរយៈពេល ៥ នាទី
៣. កុមារដែលរកឃើញស្ករគ្រាប់បានច្រើនជាងគេគឺជាអ្នកឈ្នះ



៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមឲ្យកុមារទាំង អស់ចែករំលែកស្ករគ្រាប់ឲ្យគ្នា ទៅវិញទៅមក

៥. សូមពន្យល់កុមារថា ការដែលយើងចែករំលែកស្ករ គ្រាប់គ្នាទៅវិញទៅមកក៏ដូចជាព្រះយេស៊ូវ យាងមកចែកចាយសេចក្តី សង្គ្រោះ ដល់មនុស្សគ្រប់គ្នាអីចឹងដែរ។

## ៨. ខគម្ពីរចងចាំ

**ទំនុកតម្កើង ៩៖១** *"ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្ត ទូលបង្គំនឹងនិទាន ពីអស់ទាំងការអស្ចារ្យរបស់ទ្រង់"*។

## ៩.ហត្ថកម្ម «ដើមឈើ"ខ្ញុំអរព្រះគុណព្រះជាម្ចាស់សម្រាប់ព្រះយេស៊ូវ"»

សម្ភារៈត្រូវការ៖ ខ្មៅដៃពណ៌ការកន្ត្រៃសូមបោះពុម្ព ដើមឈើកោណ(មើលនៅទំព័រខាងក្រោម)






១. សូមបោះពុម្ពដើមឈើកោណសម្រាប់សិស្សគ្រប់គ្នា

២.ឱ្យកុមារកាត់រូបនោះ(ឬគ្រូអាចកាត់វាឱ្យកុមារក៏បាន)

៣. ឲ្យកុមារតុបតែងឬផាត់ពណ៌ដើមឈើនោះ

៤.បន្ទាប់មកបិទការសងខាង ដើម្បីធ្វើជាដើមគ្រីស្មាស

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវមិនចាំបាច់មករកយើងក្នុងនាមជាទារកដែលគ្មានទីពឹងនោះទេ។ ទ្រង់យាងមកដោយសារយើងត្រូវការសេចក្តីសង្គ្រោះ ដើម្បីត្រឡប់ទៅឯព្រះវរបិតាវិញ។ អរគុណព្រះជាម្ចាស់ដែលបានបញ្ជូនព្រះ យេស៊ូវមកសង្គ្រោះយើងពីអំពើបាប និងសេចក្តីស្លាប់។ ចូរអធិស្ឋានដល់ព្រះដើម្បីឲ្យទ្រង់ប្រទានប្រាជ្ញាដល់អ្នក ដើម្បីជួយកុមារឲ្យយល់ពីសារៈសំខាន់នៃការអរព្រះគុណដល់ព្រះជាម្ចាស់ សម្រាប់ព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះនៃពិភពលោក។

ល្មើញាះយា

លុឌហប់ងះយាេអខ៉ុ